# វិរបុរសជាតិ ?

ខ្ញុំ ធ្លាប់ បាន សរសេរ អត្ថបទ មួយ ជា ភាសា បារាំង ដាក់ ចំណងជើង ថា « នគរ មួយ គ្មាន វិរបុរស ជាតិ » នៅ ក្នុង គតិ (esprit) របស់ ខ្ញុំ គឺ ខ្ញុំ ចង់ បង្ហាញ មតិផ្ទាល់ខ្លួន ដល់ មហាជន ខ្មែរ ថា នៅ ក្នុង សង្គម ខ្មែរ នៅ មិន ទាន់ មាន ឯកភាព នៅ ឡើយ ទៅ លើ សកម្មភាព របស់ បុគ្គល ណា ម្នាក់ ដែល អាច ឲ មតិ សាធារណ:ជន បំពាក់ ងារ ដល់ ជន នោះ ជា វិរបុរសជាតិ ព្រោះ ស្រុក ខ្មែរ យើង តាំង ពី អតីតកាល មក ដល់ បច្ចុប្បន្នកាល នៅ រស់ ជា និច្ច ក្នុង ឥទ្ធពល អំណាច នយោបាយ ឥត មាន កំរិត ដែល វា នាំ ឲ មាន ភាព ច្របូក ច្របល់ សំរាប់ ធ្វើ ការវិនិច្ឆ័យ រក ការពិត លើ អំពើ ល្អ អំពើ អាក្រក់ សំរាប់ ជាតិ ដែល សុទ្ធ ជា អំពើ មាន ការ ជាប់ ទាក់ ទិន ជា និច្ច ក្នុង អំណាច នយោបាយ ដែល វា អាច កែខៃ បាន ស ជា ខ្មៅ ឬ ខ្មៅ ជា ស។

អំណាច អាច កែខៃ បាន នេះ ឯង ដែល នាំ ឲ ខ្មែរ យើង មាន ការសង្ស័យ ច្រើន ទៅ លើ អ្វី ដែល មាន ចារ ទុក ក្នុង ប្រវត្តិសាស្ត្រ ជា ពិសេស ប្រវត្តិសាស្ត្រ នយោបាយ ដែល វា អាច មាន លក្ខណ: ជា ការសរសេរ សរសើរ ហួសហេតុ ចំពោះអ្នក ដឹកនាំ ដែល អ្នក និពន្ធ ណា ម្នាក់ គេ លើក យក មក សរសេរ តាម ការបញ្ជា ពី សំណាក់ អ្នក មាន អំណាច ដែល ខ្លួន ជា អ្នក បំរើ ឬ គ្រាន់

ជា ការបញ្ចេញ មតិផ្ទាល់ខ្លួន ព្រោះ ខ្លួន មាន ការស្ញប់ស្ញែង ទៅ លើ ស្នាដៃ ឬ គុណសម្បត្តិ របស់ អ្នក ដឹកនាំ ណា ម្នាក់ តែ ប៉ុណ្ណោះ ដូចយ៉ាង អ្នក សីហនុនិយម គេ ទុក សព សីហនុ ជា វីរបុរសជាតិ, ចុះ ហេតុ អ្វី ក៏ ពួក ខ្មែរ ក្រហម មិន អាច ធ្វើ វិទ្ធង្សនា ថា ប៉ុល ពត ជា វីរសបុរស ជាតិ បាន ផង ដែរ ? ព្រោះ សីហនុ និង ប៉ុល ពត ជា មិត្ត រួម អាវុធ ផង និង ជា មិត្ត រស់ រួម ក្នុង វង្ស កុម្មុយនិស្ត ផង ហើយ មាន វីរបុរស រួម តែ មួយ ទៅ ទៀត គឺ ម៉ៅ សេងទុង។

ការពិបាក ដែល មាន ក្នុង ប្រវត្តិសាស្ត្រ នយោបាយ ខ្មែ គឺ ការ គូស ព្រំ ដែន រវាង ប្រវត្តិវិទ្យា នឹង អ្វីៗ ដែល បុគ្គល ណា ម្នាក់ បាន ឃើញ ដោយ ភ្នែក ហើយ យក មក សរសេរ ជា ការចងចាំ ទុក សំរាប់ មហាជន ឬ ការសរសេរ សំរាប់ ឃោសនា នយោបាយ ជា ផ្លូវការ ក្តី ឬ លាក់ មុខ ក្តី។ ក្នុង ចំណុច នេះ យើង សួរ ថា តើ អភិញ្ញាណ ណា មួយ ដែល ខ្មែរយើង អាច ទុក ជា ប្រវត្តិវិទ្យា ឬ ជា និក្ខេបបទ ជា ផ្លូវការ របស់ ជាតិ ខ្មែរ ? ចំពោះ អ្នក ប្រវត្តិសាស្ត្រ បរទេស ល្បីល្បាញ ដែល គេ ទុក ជា អ្នក ជំនាញ នៃ ប្រវត្តិសាស្ត្រ ខ្មែរ ជា ពិសេស ជន ជាតិ បារាំង បាន ចែក ច្បាស់ ថា អ្វី ដែល ទុក ស្នាម តាម ការសរសេរ ក្តី តាម សក្ខីកម្ម ជា សំដី ក្តី ជា ការចងចាំ ក្តី មាន មុន និង ក្រោយ សម័យ អង្គរ ច្រើន មាន លាយឡំ ដោយ រឿង ព្រេង ជាង ប្រវត្តិវិទ្យា ព្រោះ

# វីរបុរសខ្មែរ

និវេទន៍[1] ទាំង នោះ គ្មាន ពស្តុតាង ជា សម្ភារៈ សំរាប់ យក មក ពិនិត្យ បញ្ជាក់ ការពិត។ តែ លោក អេង សុត អ្នក ស្រាយជ្រាវ ប្រវត្តិសាស្ត្រ ខ្មែរ ដ៏ល្បី ម្នាក់[2] មាន យោបល់ ថា ឯកសារ សរសេរ ដោយ បុព្វបុរស ខ្មែរ អំពី ប្រវត្តិសាស្ត្រ ក្រោយ សម័យ អង្គរ មាន ជាប់ ពិត រឿង ព្រេង របស់ ព្រះបាទ ត្រសក់ផ្អែម ប៉ុន្តែ បើ នឹង កាត់ចោល វា នាំ ឲ្យ អ្នក អាន មើល មិន យល់, ប៉ុន្តែ បន្ត មក ទៀត មាតិកា ក្នុង ឯកសារ បុរាណ ខ្មែរ នោះ ចាប់ ផ្តើម មាន លក្ខណៈ ជា ប្រវត្តិវិទ្យា ពិត, ទស្សនៈ នេះ ត្រូវ ប្រវត្តិវិទូ បារាំង ខ្លះ គេ បាន យល់ ស្រប តាម ដែរ ។ យើង ឃើញ ថា លោក អេង សុត លោក មាន ការ ប្រុង ប្រយ័ត្ន ណាស់ ក្នុង ការ ប្រើពាក្យ ដូច យ៉ាង  យក ពាក្យ « មហា បុរស » តែ មិន ប្រើ ពាក្យ « វីរបុរស » ព្រោះ ថា ពាក្យ វីរបុរស ជា ពិសេស ក្នុង សភាពការណ៍ នយោបាយ នៅ ក្នុង ស្រុក ខ្មែរ តាំង ពី ប្រទេស បាន ឯករាជ្យ មក នាំ បង្កើត ជា សង្គ្រាម មតិ ឬ ប៉ាកកា (polémique) នៅ ក្នុង មជ្ឈដ្ឋាន អ្នក ចេះដឹងខ្មែរ គ្រប់ថ្នាក់។ ពាក្យ មហា បុរស គឺ គ្រាន់ តែ ទុក បុគ្គល ម្នាក់ បាន ធ្វើ កិច្ច ការ ដ៏ សំខាន់ អ្វី មួយ ដែល ទុក ស្នាម ក្នុង ប្រវត្តិសាស្ត្រ ជាតិ, ដូច្នេះ ពាក្យ នេះ អាច ជា ពាក្យ អព្យាក្រឹត ក្នុង គតិ អ្នក ចេះ ដឹង ខ្មែរ, ជា ពាក្យ បើក ចំហរ ឲ្យ អ្នក អាន មាន លទ្ធភាព ធ្វើ

---

[1] និវេទន៍=ការឲដឹង។

[2] ឯកសារស្រាវជ្រាវ ដោយលោកអេងសុត”មហាបុរសខ្មែរ”ឬ”ព្រះរាជពង្សាវតាខ្មែរ” ជាឯកសា ដកស្រង់ពីសាស្ត្រាវិត, តែ លោក យកមក សរសេរ ជា អក្ខរាវិរុទ្ធសម័យ ដើម្បីឲបច្ឆាជនខ្មែរសព្វថ្ងៃអាចអានបានងាយស្រួល។

ការវិនិច្ឆ័យ ដោយ ខ្លួន ឯង ទៅ លើ ស្នាដៃ បុគ្គល ណា ម្នាក់ ដែល មាន ទុក ស្នាម ស្នាដៃ ក្នុង ប្រវត្តិសាស្ត្រ ជាតិ, ការបារម្ភ ធំ មួយ ទៀត របស់ លោក អេង សុត គឺ លោក មិន ចង់ ឲ្យ អ្នក ផង ឯ ទៀត ចោទ លោក ថា លោក ជា មហិច្ឆិតាជន ហ៊ាន វិនិច្ឆ័យ ចាត់ តាំង បុព្វបុរស ខ្មែរ ណា ម្នាក់ ជា វិរបុរស ព្រោះ លោក យល់ ឃើញ ថា បុគ្គល ម្នាក់ មិន អាច មាន សិទ្ធិ អះអាង ថា ជន នេះ ជន នោះ ជា វិរបុរស ជាតិ នោះ ឡើយ, គុណភាព នៃ វិរបុរស នេះ វា ត្រូវ មាន ការ ដឹងឮ ទទួល ស្គាល់ ជា សាធារណៈ ឬ ជា ការកំណត់ ពី ស្ថាប័ន ជាតិ ដែល មាន នីតិ សម្បទា អាច សំរេច បាន។

យើង លើក បញ្ហា នេះ មក និយាយ ពុំ មែន មាន បំណង ឃាត់ ឃាំង អ្នក ផង ឯ ទៀត មិន ឲ្យ មាន សិទ្ធិ បំពាក់ ងារ ឲ្យ វរជន ណា ម្នាក់ ជា វិរបុរស នោះ ឡើយ ព្រោះ សិទ្ធិ នេះ ជា សេរីភាព របស់ មនុស្ស ម្នាក់ៗ ប៉ុន្តែ ការប្រើ សេរីភាព នេះ ពុំ គួរ យក មក ធ្វើ ជា ការពោល អះអាង ថា អ្វី ដែល ខ្លួន ទុក ជា សរណៈ ឬ ជា អត្តជំនឿ គឺ ជា សេចក្តីពិត ដាច់ ខាត នោះ ឡើយ ព្រោះ ដូច យើង បាន ពិពណ៌នា ខាង លើ រួច មក ហើយ អំពី ងារ វិរបុរស នេះ វា មាន ភាព ប្រែប្រួល ជា និច្ច នៅ ក្នុង ប្រទេស ណា ដែល មិន ទាន់ មាន ស្ថិរភាព នយោបាយ និង មិន ទុក ប្រជាពលរដ្ឋ ជា ប្រជាធិបតី។

ឧទាហរណ៍ ដូច ជា អ្នក ស្នេហាជាតិ ពោរកំបោរ, អាចារ្យស្វា, ក្រឡាហោមគង់, ឧកញ៉ាឈូក, ស៊ឹងង៉ុកថាញ់, ប៉ាចឈឺន, ស៊ឹម វ៉ា, អៀវកើស..ល..សុទ្ធ ជា វិរជន ហ៊ាន ងើប ប្រឆាំង នឹង អាណានិគម បារាំង ដែល ខ្មែរ អ្នក ស្នេហាជាតិ យើង ភាគ ច្រើន ក្នុងសហកាល, ទុក អស់ លោក ជា វិរបុរស,តែ ផ្ទុយ ទៅ វិញ ពួក អ្នក គាំទ្រ របប រាជានិយម, កុម្មុយនិស្ត, ពួក គេ មិន បាន ទុក អ្នក ស្នេហាជាតិ ទាំង នោះ ជា វិរបុរស ជាតិ នោះ ឡើយ។ នេះ ហើយ ជា ការបញ្ជាក់ ពី ភាព ប្រែប្រួល នៃ ងារ វិរបុរស នៅ ក្នុង គតិ ខ្មែរ គឺ វិរបុរស ជាតិ គ្មាន ទេ, មាន តែ វិរបុរស របស់ ពួក និយម អ្វី មួយ (isme) តែ ប៉ុណ្ណោះ។

ចំពោះ ខ្ញុំ ផ្ទាល់ , ខ្ញុំ ចង់ ណាស់ ឲ មាន វិរបុរស ជាតិ, តែ ជា អកុសល របស់ ស្រុក ខ្មែរ យើ  ដែល ជា នគរ រស់នៅ ជា និច្ច ក្រោម របប ផ្តាច់ការ និង នៅ ក្រោម អាណានិគម យួន, មិន តែ ប៉ុណ្ណោះ ជនខ្មែរ ច្រើន ណាស់ មាន គំនិត ងាប់ ស្លូក, មិន ចង់ រើ ខ្លួន ឲ រួច ពីសភាពការណ៍ នេះ ព្រោះ ខ្លាច សម្លាប់ ឬ ខ្លាច បាត់ អត្ថប្រយោជន៏។ សំណួរ សួរ ថា តើ ខ្មែរយើង ត្រូវ នាំ គ្នា រស់នៅ ក្នុង ភាព ទ័លច្រក នេះ ជា និច្ច ឬ ? មិន បាន ទេ ព្រោះ វា ជា ផ្លូវ មរណ: សំរាប់ ប្រជាជាតិ ខ្មែរ, តែ ខ្មែរយើង ក៏ ពុំ អាច នាំ គ្នា កែប្រែ គំនិត បែប អ្នក កំពុង លង់ទឹក នោះ ដែរ គឺ នាំ គ្នា ស្រវ៉ា ចាប់ អ្វីៗ ឲ តែ បាន រស់ សិន ដូច យ៉ាង ស្រវ៉ា ចាប់ យក ប្រវត្តិសាស្ត្រ យក មក ធ្វើ ជា អាវុធ ឬ ជា

គុលាការ សំរាប់ បំរើ ប្រយោជន៏ នយោបាយ ដោយ មិន បាន យក វា មក ពិចារណា រក ការពិត ដើម្បី ទុក ជា មេរៀន សំរាប់ សំគាល់ អ្វី ជា វិជ្ជមាន, ជាអវិជ្ជមាន, សំរាប់ ជាតិ។ ដូច យ៉ាង ប្រវត្តិវិទូ ធំៗ ក្នុង សកលលោក, លោក តែង តែ យក វិធីការ ប្រុង ប្រយ័ត្ន[3] ជា វិន័យ ក្នុង សិក្ខាបទ មេរៀន ប្រវត្តិវិទ្យា របស់ លោក ដូច មាន នៅ ក្នុង ការបារម្ភ របស់ លោក អេង សុត នោះ ដែរ។

សេចក្តី សន្និដ្ឋាន, ខ្ញុំ លើក យក សំដី អ្នក និពន្ធ បារាំង ម្នាក់ ឈ្មោះ Paul Dreyfus ជូន ជា មតិ សំរាប់ ខ្មែរយើង យក ទៅ ពិចារណា ដែល មាន សេចក្តី ដូច ខាង ក្រោម នេះ :

« នៅ ក្នុង ប្រវត្តិសាស្ត្រ ខ្មែរ ដ៏ វែង អន្លាយ អាច ធ្វើ សង្ខេប បាន លើ សភាពការណ៏ ពីរ ដែល មាន ទស្សនៈ ផ្ទុយគ្នា ; នៅ ពេលណា ជាតិខ្មែរ ខ្លាំង, ខ្មែរ តែង តែ ចិញ្ចឹម ទឹកចិត្ត មើល ងាយ ជាតិ សៀម និង យួន ជា និច្ច, តែ នៅ ពេល ជាតិខ្មែរ ខ្សោយ, គឺ ច្បាស់ ជា ត្រូវ ជាតិ សៀម និង យួន ដែល ជា អ្នក ជិតខាង មិន ល្អ ឈ្លៀត លួច ទឹកដី ខ្មែរ ហើយ ពេល ខ្លះ គឺ ផ្លូន់ យក តែ ម្តង[4] »

---

[3] វិធីប្រុងប្រយ័ត្ន=Règle de prudence។

[4] Paul Dreyfus – Pol Pot, le bourreau du Cambodge Edition Stock,2000) : Toute la longue histoire des Khmers peut se résumer à deux situations antithétiques : ou bien le Cambodge est puissant et il nourrit une hostilité méprisante envers l’Annam et le Siam ; ou bien le Cambodge est faible et alors il est grignoté, parfois même presque dévoré par ses deux mauvais voisins។

សួរ ថា តើ ខ្មែរយើង ទុក បុព្វបុរស ខ្មែរ ណា ម្នាក់ ជា វិរបុរស ដោយសារ បុព្វបុរស នោះ ជា អ្នក មាន ជ័យជំនះ លើ ជាតិ សៀម និង យួន តែ ប៉ុណ្ណោះឬ ? ហើយ បច្ចុប្បន្ន នេះ, អ្នក ណា ជា អ្នក ឈ្នះខ្មែរ ?